# ការវាយតម្លៃបឋមលើផលប៉ះពាល់
# សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ
# ក្រសួងអប់រំ យុវជន និងកីឡា

លេខយោង:

កាលបរិច្ឆេទចាប់ផ្តើម:

កាលបរិច្ឆេទបញ្ចប់:

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

អនុក្រឹត្យនេះ កំណត់អំពីការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ ក្នុងគោលដៅសម្រិតសម្រាំងសិស្សពូកែទូទាំងប្រទេស លើកទឹកចិត្តសិស្សនៅមធ្យមសិក្សាឱ្យផ្តោតការយកចិត្តទុកដាក់រៀនសូត្រ និងផ្តល់តម្លៃដល់ជ័យលាភីសិស្សពូកែ ដែលមានប្រាក់រង្វាន់លើកទឹកចិត្តពីលេខ១ ដល់ លេខ១០ ត្រូវចំណាយថវិកាជាតិប្រមាណ ៦៤ ០០០ ០០០៛ (ហុកសិបបួនលានរៀល) ក្នុងមួយឆ្នាំសិក្សា។ បុគ្គល បុព្វជិត គ្រួសារ សហគមន៍ សង្គមស៊ីវិល ស្ថាប័នរដ្ឋ និងឯកជនទាំងអស់ មានសិទ្ធិផ្តល់រង្វាន់ជាសម្ភារៈ ឬថវិកាជូនជ័យលាភីសិស្សពូកែ។

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះជ័យលាភីសិស្សពូកែទូទាំងប្រទេសនៅតាមគ្រឹះស្ថានមធ្យមសិក្សាចំណោះទូទៅសាធារណៈនិងឯកជន។

## ប្រភេទបញ្ញត្តិកម្ម

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖

☐សេដ្ឋកិច្ច ☑សង្គមកិច្ច ☐បរិស្ថាន ☐ផ្សេងៗ (អប់រំ)

## ១. ការកំណត់បញ្ហា

១.ក បញ្ហាចម្បងដែលបញ្ញត្តិកម្មមានបំណងដោះស្រាយ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

**១. ប្រាក់រង្វាន់លើកទឹកចិត្តមានចំនួនតិច**

ប្រាក់រង្វាន់លើកទឹកចិត្តមានគម្លាតខុសគ្នារវាងផ្នែកអប់រំ និងផ្នែកកីឡា ដែលស្ថិតក្នុងស្ថាប័ន/វិស័យតែមួយ ដោយផ្នែកកីឡាមានប្រាក់រង្វាន់លើកទឹកចិត្តខ្ពស់ខ្លាំងជាងផ្នែកអប់រំ។ ដូច្នោះដើម្បីចូលរួមលើកកម្ពស់ផ្នែកទាំងពីរឱ្យមានភាពប្រហាក់ប្រហែលគ្នា ក្រសួងក៏គួរគាំទ្រនិងជំរុញផ្នែកអប់រំ ពិសេសលើការខិតខំប្រឹងប្រែងរៀនសូត្ររបស់សិស្សានុសិស្ស ក្នុងន័យឆ្លើយតបទៅនឹងកំណែទម្រង់ក្នុងវិស័យអប់រំ ទាក់ទងនឹងការកសាងសមត្ថភាព និងអភិវឌ្ឍធនធានមនុស្ស ដែលជាមូលដ្ឋានរឹងមាំនៃផ្នែកបញ្ញា ស្មារតីរបស់សិស្ស និងជាកាតាលីករមួយ

ចូលរួមអភិវឌ្ឍន៍សេដ្ឋកិច្ចប្រទេសកម្ពុជា ដែលសង្ឃឹមថានឹងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ខាងមុខ។

កត្តាខាងលើ ជាមូលហេតុជំរុញឱ្យក្រសួងគួរបង្កើនការយកចិត្តទុកដាក់លើលទ្ធផលសិក្សារបស់សិស្សពូកែ ពិសេសគួរបន្ថែមលើប្រាក់រង្វាន់លើកទឹកចិត្តរបស់ពួកគាត់ ។

**២. ប្រកួតប្រជែងលើឆាកអន្តរជាតិ**

ធនធានមនុស្សជាកត្តាសំខាន់ និងជាបរិបទសកល មិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍប្រទេស។ យោងលើប្រទេសកម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍ ការអភិវឌ្ឍន៍ធនធានមនុស្សប្រកបដោយគុណភាព សមត្ថភាព ទេពកោសល្យ និងសក្តានុពលសម្រាប់ធានាការអភិវឌ្ឍសង្គម សេដ្ឋកិច្ចជាតិប្រកបដោយចិរភាព ទាមទារឱ្យមានការប្រកួតប្រជែងនៃការរីកចំរើននៃបច្ចេកវិជ្ជាយ៉ាងខ្លាំងទាំងក្នុងតំបន់ និងពិភពលោក។ ដើម្បីទទួលបានភាពជោគជ័យលើឆាកអន្តរជាតិ ក្រសួងអប់រំ យុវជន និងកីឡា ដើរតួរយ៉ាងសំខាន់ក្នុងការពង្រឹងគុណភាពអប់រំ ទាំងទ្រឹស្តី និងការអនុវត្ត (ការពិសោធន៍) ពិសេសការលើកតម្លៃដល់សិស្សពូកែ ដើម្បីជាមោទនភាពរបស់សិស្សានុសិស្ស មាតាបិតា សាលារៀន សង្គមជាតិ និងពិភពលោក តាមរយៈការបង្កើតប្រាក់រង្វាន់លើកទឹកចិត្ត។

**៣. ការប្តូរមុខវិជ្ជារូបវិទ្យា ទៅ ជាវិទ្យាសាស្ត្រ**

រូបវិទ្យាជាមុខវិជ្ជាមួយក្នុងបណ្តុំមុខវិជ្ជាវិទ្យាសាស្ត្រ ដែលមានមុខមុខវិជ្ជាបីសំខាន់គឺរូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ហើយរាល់ការប្រឡងសិស្សពូកែថ្នាក់តំបន់ និងពិភពលោកគឺគេផ្តោតលើមុខវិជ្ជាវិទ្យាសាស្ត្រ ដែលក្តោបមុខវិជ្ជាទាំងបីខាងលើ។ ដូច្នោះដើម្បីជាមូលដ្ឋានគ្រឹះអភិវឌ្ឍសមត្ថភាពរបស់សិស្សានុសិស្សឱ្យបានទូលាយ និងស្របតាមលក្ខខណ្ឌប្រឡងនានាខាងលើ ក្រសួងអប់រំ យុវជន និងកីឡា បានកែសម្រួលមុខវិជ្ជាពី «រូបវិទ្យា» ទៅ «វិទ្យាសាស្ត្រ» លើចំណងជើងនៃសេចក្តីព្រាងអនុក្រឹត្យនេះ។

១.ខ បញ្ហាពាក់ព័ន្ធផ្សេងទៀតដែលបញ្ញត្តិកម្មអាចជួយដោះស្រាយផងដែរ ដោយផ្តល់អំណះអំណាង (ភស្តុតាង/ភាពជាក់ស្តែង ប្រសិនបើចាំបាច់)

- អនុក្រឹត្យលេខ០៦ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែកគណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា...។

១.គ សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។ ចូរបញ្ជាក់ថា តើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះ មិនទាន់គ្រប់គ្រាន់?

- ច្បាប់ស្តីពីការអប់រំ ឆ្នាំ២០០៧ ត្រង់**មាត្រា៣៨ ការអប់រំពិសេស** បានចែងថា « រដ្ឋលើកទឹកចិត្ត និងជំរុញឱ្យមានការអប់រំពិសេសសម្រាប់ជនពិការ និងអ្នកសិក្សាពូកែដែលមានទេពកោសល្យ និង/បញ្ញាខ្ពស់»
- អនុក្រឹត្យលេខ ០៦ អនក្រ. ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការរៀបចំថ្នាក់សិស្សពូកែផ្នែក

| |
|---|
| គណិតវិទ្យា អក្សរសិល្ប៍ខ្មែរ និងរូបវិទ្យា បានផ្តល់រង្វាន់មានកម្រិតទាបបើប្រៀបធៀបស្ថានភាពបច្ចុប្បន្ន។ |

១. ឃ តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ? (ប្រសិនបើមានសូមពន្យល់)

| |
|---|
| សំណើបញ្ញត្តិកម្មនេះ មិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែង(ជាលក្ខណៈពាណិជ្ជកម្ម)ឡើយ។ |

**២. គោលបំណង** តើយើងចង់សម្រេចបានអ្វី?

| |
|---|
| ការរៀបចំសេចក្តីព្រាងអនុក្រឹត្យនេះឡើង ក្នុងគោលបំណងដោះស្រាយបញ្ហាខាងលើទាំងប៉ុន្មានតាមរយៈ ការបង្កើនប្រាក់រង្វាន់លើកទឹកចិត្តសិស្សពូកែ ការជម្រុញ និងលើកទឹកចិត្តសិស្សពូកែឱ្យមានការប្រកួតប្រជែងសមត្ថភាពទាំងក្នុងតំបន់ និងពិភពលោក និងកៀរគរការចូលរួមលើកទឹកចិត្តដល់សិស្សពូកែ។ |

**៣. ជម្រើស**

ជម្រើសផ្សេងៗរួមទាំងសំណើបញ្ញត្តិកម្ម (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១. បន្តអនុវត្តអនុក្រឹត្យលេខ ០៦ អនក្រ.បក ដែលមានស្រាប់<br>២. សំណើអនុក្រឹត្យថ្មី |

**៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់ព័ន្ធ និងផលចំណេញ**

៤.១ ការកំណត់ភារកិច្ច និងប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តអនុក្រឹត្យលេខ ០៦ អនក្រ.បក ដែលមានស្រាប់ | - បន្ទុកចំណាយសម្រាប់គណៈប្រតិភូមកពីតាមបណ្តាខេត្ត ប្រហែល **៧៥១ ១១០ ០០០** រៀល<br>- បន្ទុកចំណាយលើការរៀបចំការប្រឡងប្រហែល **៤០ ២៩៤ ៤០០** រៀល<br>- បន្ទុកចំណាយលើការផ្តល់រង្វាន់ដល់ជ័យលាភីប្រហែល **១៩ ៩៥០ ០០០** រៀល<br>ចំណាយសរុបប្រហែល **៨១១ ៣៥៤ ៤០០** រៀល ស្មើនឹង **២០២ ៨៣៨ $** | - គ្មាន |

| | | |
|---|---|---|
| ជម្រើសទី២៖ សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ | - បន្ទុកចំណាយសម្រាប់គណៈប្រតិភូមកពីតាមបណ្តាខេត្តប្រហែល **៧៥១ ១១០ ០០០** រៀល<br>- បន្ទុកចំណាយលើការរៀបចំការប្រឡងប្រហែល **៤០ ២៩៤ ៤០០** រៀល<br>- បន្ទុកចំណាយលើការផ្តល់រង្វាន់ដល់ជ័យលាភីប្រហែល **៦៥ ៥០០ ០០០** រៀល<br>ចំណាយសរុបប្រហែល **៨៥៦ ៩០៤ ៤០០** រៀល ស្មើនឹង **២១៤ ២២៦** $ | - គ្មាន |

៩.២ ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្តអនុក្រឹត្យលេខ ០៦ អនក្រ.បក ដែលមានស្រាប់ | - រក្សាស្ថានភាពដើម។<br>- ផលចំណេញបានតិចតួច ដោយសិស្សពូកែនៅតែទទួលបានរង្វាន់តិច | - គ្មាន |
| ជម្រើសទី២៖ សេចក្តីព្រាងអនុក្រឹត្យស្តីពីការផ្តល់រង្វាន់ដល់ជ័យលាភីសិស្សពូកែផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រន៍ | - បានបង្ហាញនូវការយកចិត្តទុកដាក់ចំពោះវិស័យអប់រំ ជាពិសេសចំពោះសិស្សពូកែ<br>- សិស្សនឹងខិតខំរៀនសូត្រ នោះធនធានមនុស្សនឹងសម្បូរណ៍បែប ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច ដោយយកមូលធនមនុស្សជាមូលដ្ឋាន<br>- កាត់បន្ថយភាពអស់សង្ឃឹមឬគំនិតអវិជ្ជមានរបស់សិស្ស។ | - គ្មាន |

៤.៣ វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១៖ បន្តអនុវត្ត អនុក្រឹត្យលេខ ០៦ អនក្រ.បក ដែលមានស្រាប់ | | | |
| ជម្រើសទី២៖ សេចក្តីព្រាង អនុក្រឹត្យស្តីពីការផ្តល់រង្វាន់ ដល់ជ័យលាភីសិស្សពូកែ ផ្នែកអក្សរសិល្ប៍ខ្មែរ គណិតវិទ្យា និងវិទ្យាសាស្ត្រ | | | |

## ៥. កិច្ចពិគ្រោះយោបល់

ទទួលបានការឯកភាពពីសំណាក់អ្នកពាក់ព័ន្ធដូចជា ពីសំណាក់ថ្នាក់ដឹកនាំក្រសួងផ្ទាល់ពីប្រមុខរាជរដ្ឋាភិបាល។

## ៦. សន្និដ្ឋាន

តើចាំបាច់ធ្វើ RIS ដែរឬទេ?

☐ចាំបាច់

☑មិនចាំបាច់

បញ្ញត្តិកម្មដែលស្នើឡើងនេះ មិនមានផលប៉ះពាល់ដល់ធុរកិច្ចឡើយ ប៉ុន្តែបញ្ញត្តិកម្មនេះនឹងផ្តល់នូវផលវិជ្ជមានសម្រាប់សិស្សានុសិស្សជាពិសេសសិស្សពូកែ។ ដូច្នេះ ជម្រើសទី២ គួរត្រូវបានជ្រើសរើស។

## ៧. ការអនុវត្តនិងការតាមដានត្រួតពិនិត្យ

៧.១ តើវិធានការអ្វីត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលនៃការប្រតិបត្តិ?

បើសិនជាសំណើរៀបចំអនុក្រឹត្យថ្មីនេះត្រូវបានជ្រើសរើស វិធានការដើម្បីលើកកម្ពស់តម្លាភាពនិងអភិបាលកិច្ចល្អក្នុងអំឡុងពេលប្រតិបត្តិ គឺត្រូវលើកកម្ពស់ប្រសិទ្ធភាពក្នុងដំណើរការប្រឡង។

៧.២ តើគួរធ្វើការពិនិត្យ/តាមដានបញ្ញត្តិកម្មនេះឡើងវិញក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានប្រតិបត្តិដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះ គួរត្រូវបានពិនិត្យឡើងវិញ / តាមដានយ៉ាងដូចម្តេច និងនៅពេលណា?

ករណីសំណើអនុក្រឹត្យថ្មីត្រូវបានជ្រើសរើស  អនុក្រឹត្យថ្មីនេះគួរត្រូវបានពិនិត្យឡើងវិញរៀងរាល់ ៥ឆ្នាំម្តង។

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ | ទំនាក់ទំនង |
|---|---|---|---|---|---|
| រៀបចំដោយក្រសួងអប់រំ យុវជន និងកីឡា | ឯកឧត្តម ស៊ិន សេងហុក | ប្រធាន | | | |
| | លោក ប៉ូវ វី | អនុប្រធាន | | | |
| | លោកស្រី ខូវ សោភ័ណ | សមាជិក | | | |
| | លោក អ៊ា ព្រំ | សមាជិក | | | |
| | លោក ស៊ាន បញ្ញា | សមាជិក | | | |
| ត្រួតពិនិត្យដោយ | លោកជំទាវ ស៊ាង សុផល្លា | | | | |
| ឯកភាពដោយ | ឯកឧត្តម ប៉ិច សុខា | | | | |